

## ខ្ញុំបានត្រៀមខ្លួនរួចរាល់ហើយ!

# តើខ្ញុំត្រូវចាប់ផ្តើមដោយវិធីណា?

វិជ្ជាស្ថានសិក្សាតាមអ៊ិនធ័រណិតនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា កំពុងទទួលពាក្យសុំចូលរៀនសម្រាប់ឆ្នាំសិក្សា ២០១៣-១៤។ មុនពេលឆ្នាំសិក្សា ចាប់ផ្តើម លោកអ្នកមានឱកាសជាច្រើនដើម្បីស្វែងយល់អំពី វិជ្ជាស្ថានសិក្សាតាមអ៊ិនធ័រណិតនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

មេសា | ឧសភា | មិថុនា | កក្កដា | សីហា

បើកទទួលចុះឈ្មោះចូលរៀន
១៥មេសា

បើកឲ្យមើលកន្លែង
២ ឧសភា តាមអ៊ិនធ័រណិត

បើកឲ្យមើលកន្លែង
៨ ឧសភា ជួបផ្ទាល់

បើកឲ្យមើលកន្លែង
១៥ ឧសភា ជួបផ្ទាល់

បើកឲ្យមើលកន្លែង
២៩ ឧសភា ជួបផ្ទាល់

បើកឲ្យមើលកន្លែង
៦ មិថុនា តាមអ៊ិនធ័រណិត

បើកឲ្យមើលកន្លែង
១១ មិថុនា ជួបផ្ទាល់

បើកឲ្យមើលកន្លែង
១៩ កក្កដា តាមអ៊ិនធ័រណិត

បើកឲ្យមើលកន្លែង
៨ សីហា តាមអ៊ិនធ័រណិត

ការណែនាំ
១៩ - ២១ សីហា

សាលាចាប់ផ្តើមរៀន
៣ កញ្ញា

យើងខ្ញុំសុំឲ្យសិស្សានុសិស្ស និងក្រុមគ្រួសារ ចូលរួមក្នុងការជួបជុំផ្តល់ព័ត៌មាន—ជួបគ្នាផ្ទាល់ ឬជួបតាមអ៊ិនធ័រណិត—ដើម្បីជួបជាមួយបុគ្គលិក និងគ្រូ ដែលជួយដល់ការសិក្សារបស់ពួកគេពីដើមរហូតដល់ចុងឆ្នាំ។

នៅពេលដែលលោកអ្នកបានសម្រេចចិត្តចុះឈ្មោះសុំចូលរៀន ការចុះឈ្មោះមានលក្ខណៈងាយស្រួល ជាវិធីធ្វើមួយជំហានម្តងៗ។ មានអ្វីៗមួយចំនួន សម្រាប់លោកអ្នកដែលជាក្រុមគ្រួសារ ត្រូវទទួលខុសត្រូវក្នុងការផ្តល់ឲ្យក្រសួង កិច្ចការផ្សេងទៀត ទទួលខុសត្រូវដោយក្រុម PVA របស់យើងខ្ញុំ ដើម្បីធ្វើយ៉ាងណាឲ្យគេដាក់កូនរបស់លោកអ្នកក្នុងថ្នាក់ និងកម្មវិធី ដែលត្រឹមត្រូវសម្រាប់ពួកគេ។ ចូរមើលអ្វីៗទាំងនេះជាមួយគ្នា៖

**តើអ្នកណាជាអ្នកបំពេញដំណាក់កាលនេះ?**

១. **ការបំពេញលិខិតចុះឈ្មោះរៀននៅ PVA។** លិខិតចុះឈ្មោះចូលរៀនដំបូងរបស់យើង មាននៅក្នុងវិបសៃ http://www.philasd.org/language/khmer/pva ។ លិខិត នេះប្រមូលព័ត៌មានសំខាន់ៗ ហើយអនុញ្ញាតឲ្យបុគ្គលិករបស់យើងខ្ញុំអាចទាក់ទងទៅលោកអ្នកអំពីការចុះឈ្មោះរៀននៅ PVA។

☐ លោកអ្នក (មាតាបិតា ឬអាណាព្យាបាល) ជាអ្នកបំពេញដំណាក់កាលនេះ។

២. **ការពិនិត្យមើលការអប់រំពិសេស។** ក្រុមប្រជុំ IEP នឹងជួបជាមួយសិស្សានុសិស្សទាំងអស់ដែលមានគម្រោងការសិក្សាសម្រាប់សិស្សម្នាក់ៗ (IEP) ដែលមានចំណាប់អារម្មណ៍ ដើម្បីធ្វើយ៉ាងណាឲ្យគម្រោងការនៅក្នុង IEP អាចសម្រេចទៅបាននៅ PVA។ បើសិនជាក្រុម ព្រមព្រៀងថា ការចាត់តាំងសិស្សជាការសមរម្យ គេនឹងផ្ញើលិខិតជូនដំណឹងអំពីសំណូមពរនៃការចាត់តាំងសិស្ស (NOREP) ដោយមានចុះហត្ថលេខាដោយមាតាបិតា។ គ្រូដែលមានវិញ្ញាបនបត្រផ្នែកអប់រំពិសេស នឹងធ្វើជាអ្នកគ្រប់គ្រង ផ្តល់ជំនួយផ្នែកការសិក្សាផ្ទាល់ ដល់សិស្សានុសិស្ស បន្ថែមទៅលើការណែនាំដល់គ្រូបង្រៀនមុខវិទ្យាសំខាន់ៗ ដើម្បីធ្វើយ៉ាងណាឲ្យពួកគេកែសម្រួលកិច្ចការសាលាតាមការតម្រូវរបស់ IEP។

*Our PVA Special Education team along with you (the parent/guardian) will complete this step.*

៣. **ការចាត់តាំងសិស្សដែលត្រូវការរៀនភាសាអង់គ្លេស។** ការតម្រូវឲ្យមាន ការអាន និងការសរសេរច្រើន ក្នុងមុខវិទ្យាសិក្សាតាមអ៊ិនធ័រណិត អាចជាបញ្ហាសម្រាប់សិស្សដែលត្រូវការរៀនភាសាអង់គ្លេស (ELLs)។ ដូច្នេះគេបានសុំឲ្យសិស្ស ELLs ដែលបានចុះឈ្មោះរៀនក្នុងកម្មវិធីសិក្សាតាមអ៊ិនធ័រណិត បង្ហាញនូវលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយការផ្តល់ពិន្ទុនៃការប្រឡងក្នុងពេលថ្មីៗ ដូចតទៅនេះ៖

- មានចំណេះដឹងគ្រប់គ្រាន់ផ្នែកភាសាអង់គ្លេស តាមការបង្ហាញដោយពិន្ទុសរុប ៣,៥ ឬខ្ពស់ជាងនេះ ក្នុងការប្រឡង Wida Access ឬការប្រឡង Wida Access សម្រាប់ការចាត់តាំងសិស្ស (W-APT)។ និង
- មានចំណេះដឹងគ្រប់គ្រាន់ផ្នែកអក្សរសាស្ត្រ ភាសាអង់គ្លេស តាមការបង្ហាញដោយពិន្ទុសរុប ៣,៥ ឬខ្ពស់ជាងនេះ ក្នុងការប្រឡង Wida Access ឬ W-APT។

គេនឹងវាយតម្លៃសិស្សម្នាក់ៗ ដើម្បីសម្រេចពីផែនការនៃកម្មវិធីបង្ហាត់បង្រៀនភាសាអង់គ្លេសដែលជាភាសាទីពីរ (ESL) ដើម្បីជួយដល់ការទទួលនូវចំណេះដឹងផ្នែកភាសាអង់គ្លេស ហើយផ្តល់កម្មវិធីបង្ហាត់បង្រៀនដែលសក្តិសមដល់ការអភិវឌ្ឍន៍ និងកម្រិតនៃការបង្ហាត់បង្រៀនរបស់សិស្ស។ ភាពសក្តិសម សម្រាប់សិស្ស ELLs ក្នុងការសិក្សាតាមអ៊ិនធ័រណិត នឹងយោងទៅលើពិន្ទុនៃការប្រឡង Wida Access ឬ W-APT របស់សិស្សានុសិស្ស។

យើងមិនចង់ឲ្យសិស្ស ELLs ដែលបានពិន្ទុក្រោម ៣,៥ ក្នុងការប្រឡង Wida Access ឬ W-APT ចូលរួមក្នុងកម្មវិធីសិក្សាតាមអ៊ិនធ័រណិតពេញម៉ោងទេ។ ទោះជាដូច្នេះក៏ដោយ កម្មវិធីសិក្សាតាមអ៊ិនធ័រណិត អាចប្រើដើម្បីផ្តល់ កម្មវិធីសិក្សា និងការបង្ហាត់បង្រៀន សម្រាប់សិស្សម្នាក់ៗ ដល់សិស្សដែលត្រូវការរៀនភាសាអង់គ្លេសណា ដែលបានពិន្ទុសរុប ៣,៥ ឬខ្ពស់ជាងនេះ ដែលបានពិន្ទុសរុបផ្នែកអក្សរសាស្ត្រ យ៉ាងតិចបំផុត ៣,៥ នៃការប្រឡង WIDA ACCESS ឬ W-APT។

☐ លោកអ្នក (មាតាបិតា ឬអាណាព្យាបាល) ជាអ្នកបំពេញដំណាក់កាលនេះ។

**តើអ្នកណាអាចរៀននៅ PVA?**

សិស្សានុសិស្ស មានអាយុក្រោម ២១ ឆ្នាំ ដែលរស់នៅ ក្នុងតំបន់របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (SDP) ដែលរៀនថ្នាក់ទី៦ ដល់ថ្នាក់ទី១២ ហើយបានរៀនចប់ពីថ្នាក់ទី៥ នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៣ អាចរៀននៅ PVA។

បន្តទៅទំព័រក្រោយ

៤. **ការផ្តល់ឯកសារដែលគេតម្រូវ។** ឯកសារដែលគេតម្រូវឲ្យមាន ដើម្បីគាំទ្រដល់ការចុះឈ្មោះរបស់កូនលោកអ្នក មានដូចតទៅ។ សូមយកឯកសារទាំងនេះទៅ 440 N. Broad Street ដើម្បីចុះឈ្មោះកូនលោកអ្នករៀននៅ PVA។ សូមទាក់ទងទៅលេខ ២១៥-៤០០-៣១១០ ដើម្បីជ្រាបព័ត៌មានបន្ថែម។

**តើអ្នកណាជាអ្នកបំពេញដំណាក់កាលនេះ?**

☐ លោកអ្នក (មាតាបិតា ឬអាណាព្យាបាល) ជាអ្នកបំពេញដំណាក់កាលនេះ។

**បើសិនជាផ្លាស់ប្តូរទៅ PVA ពីក្រសួងអប់រំផ្សេងទៀត៖**

☐ ឧស្ថាភាពបញ្ជាក់ពីអាយុ (សំបុត្រកំណើតតាមផ្លូវការ សំបុត្រលាងបាប លិខិតពីមាតាបិតា ឬសាច់ញាតិផ្សេងទៀត ប្រាប់ពីថ្ងៃកំណើត ដោយមានបោះត្រាបញ្ជាក់ លិខិតឆ្លងដែនដែលមានសុពលភាព ឯកសារពីសាលាចាស់ដែលបង្ហាញពីថ្ងៃកំណើត)។

☐ ឧស្ថាភាពបញ្ជាក់ពីទីលំនៅ (ត្រូវការឯកសារពីរ (២) ក្នុងចំណោមឯកសារទាំងនេះ៖ ប័ណ្ណកម្មសិទ្ធផ្ទះ កិច្ចសន្យាជួលផ្ទះ សំបុត្រទឹក/ភ្លើង ថ្មីៗ វិក័យប័ត្រ credit card ថ្មីៗ វិក័យប័ត្រ ពន្ធផ្ទះ ប័ណ្ណសម្គាល់រថយន្ត លិខិតបើកបររថយន្ត អត្តសញ្ញាណប័ណ្ណពីក្រសួងយានជំនិះ)។

☐ ឯកសារចាក់ថ្នាំបង្ការរោគ (លិខិតពីក្រសួងអប់រំចាស់ ឬពីការិយាល័យពេទ្យ ដែលបានចាក់ថ្នាំបង្ការរោគតាមតម្រូវការទាំងអស់ ឬកំពុងនៅក្នុងការស្នើសុំចាក់ជាបន្តបន្ទាប់ ឬការធានាអះអាងជាពាក្យសំដីពីក្រសួងអប់រំចាស់ ឬការិយាល័យពេទ្យ ថាបានចាក់ថ្នាំបង្ការរោគរួចរាល់តាមតម្រូវការហើយ ដោយមានឯកសារបញ្ជាក់ដែលនឹងផ្ញើមកតាមក្រោយ)។

☐ ការស្ទង់មតិអំពីភាសាដែលនិយាយនៅផ្ទះ (បំពេញតាមអ៊ិនធ័រណិត សម្រាប់សិស្សដែលចុះឈ្មោះលើកទីមួយ)។

☐ សម្រាប់សិស្សានុសិស្សថ្នាក់ទី៦ ដល់ ថ្នាក់ទី៩ ទាំងអស់៖ របាយការណ៍ពិន្ទុក្នុងពេលថ្មីៗ។

☐ សម្រាប់សិស្សានុសិស្សថ្នាក់ទី១០ ដល់ ថ្នាក់ទី១២ ទាំងអស់៖ ព្រឹត្តិបត្រពិន្ទុក្រៅផ្លូវការ ពីវិទ្យាល័យដែលអ្នកទៅរៀនក្នុងពេលបច្ចុប្បន្ននេះ បង្ហាញពីពិន្ទុមធ្យមភាគ និងមុខវិទ្យាដែលបានរៀនចប់។

☐ សម្រាប់សិស្សានុសិស្សដែលមាន IEP ឬ IEP សម្រាប់សិស្សឆ្លាត (GIEP) សូមផ្តល់លិខិតទាំងពីរខាងក្រោមនេះ៖

- ☐ IEP របស់សិស្សក្នុងពេលថ្មីៗមួយច្បាប់ (គម្រោងការសិក្សាសម្រាប់សិស្សម្នាក់ៗ) ឬ IEP សម្រាប់សិស្សឆ្លាត និង
- ☐ របាយការណ៍ពីការវាយតម្លៃ (មានសុពលភាពសម្រាប់រយៈពេលបីឆ្នាំ)។

☐ សម្រាប់សិស្សានុសិស្ស 504 (ការធ្វើតាមសេចក្តីត្រូវការដោយសារបញ្ហាសុខភាពអ្វីមួយ)៖ គម្រោងការធ្វើតាមសេចក្តីត្រូវការ 504 របស់សិស្សក្នុងពេលថ្មីៗមួយច្បាប់។ បើសិនជាការចុះឈ្មោះរៀននៅ PVA ពីក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

បន្តទៅទំព័រក្រោយ

## បើសិនជាផ្លាស់ប្តូរទៅ PVA ពីក្រសួងអប់រំផ្សេងទៀត៖

- ☐ លិខិតផ្លាស់ប្តូរសាលាដោយស្ម័គ្រចិត្ត – Ett-36 (ដោយសារលោកអ្នកជ្រើសរើសទៅរៀននៅសាលានេះ ចៀសជាងទៅសាលាដែលនៅជិតជាងគេរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ការចុះឈ្មោះរបស់អ្នកត្រូវចាត់ទុកថាជា ការផ្លាស់ប្តូរសាលាដោយស្ម័គ្រចិត្ត)។
- ☐ សម្រាប់សិស្សានុសិស្សថ្នាក់ទី៦ ដល់ ថ្នាក់ទី៨ ទាំងអស់៖ របាយការណ៍ពិន្ទុក្នុងពេលថ្មីៗ។
- ☐ សម្រាប់សិស្សានុសិស្សថ្នាក់ទី១០ ដល់ ថ្នាក់ទី១២ ទាំងអស់៖ ព្រឹត្តិបត្រពិន្ទុក្រៅផ្លូវការ ពីវិទ្យាល័យដែលអ្នកទៅរៀនក្នុងពេលបច្ចុប្បន្ននេះ បង្ហាញពីពិន្ទុមធ្យមភាគ នឹងមុខវិទ្យាដែលបានរៀនចប់។
- ☐ សម្រាប់សិស្សានុសិស្សដែលមាន IEP ឬ IEP សម្រាប់សិស្សឆ្លាត (GIEP) សូមផ្តល់លិខិតទាំងពីរខាងក្រោមនេះ៖
    - ☐ IEP របស់សិស្សក្នុងពេលថ្មីៗមួយច្បាប់ (គម្រោងការសិក្សាសម្រាប់សិស្សម្នាក់ៗ) ឬ IEP សម្រាប់សិស្សឆ្លាត និង
    - ☐ របាយការណ៍ពីការវាយតម្លៃ (មានសុពលភាពសម្រាប់រយៈពេលបីឆ្នាំ)។
- ☐ សម្រាប់សិស្សានុសិស្ស 504 (ការធ្វើតាមសេចក្តីត្រូវការដោយសារបញ្ហាសុខភាពអ្វីមួយ)៖ គម្រោងការធ្វើតាមសេចក្តីត្រូវការ 504 របស់សិស្សក្នុងពេលថ្មីៗមួយច្បាប់។

## តើអ្នកណាជាអ្នកបំពេញដំណាក់កាលនេះ?

- ☐ លោកអ្នក (មាតាបិតា ឬអាណាព្យាបាល) ជាអ្នកបំពេញដំណាក់កាលនេះៗ

បន្តទៅទំព័រក្រោយ

៥. **បញ្ចប់ការប្រឡងសម្រាប់ការចាត់តាំងនៅ PVA។** ការចាត់តាំងមុខវិជ្ជាឲ្យបានត្រឹមត្រូវគឺជាការសំខាន់ ចំពោះជោគជ័យរបស់សិស្ស ដែលសិក្សាតាមអ៊ិនធ័រណិត។ ការប្រឡងសម្រាប់ការចាត់តាំងនៅ PVA គឺធ្វើយ៉ាងណាឲ្យការចុះឈ្មោះរៀនមុខវិទ្យាដែលសិក្សាតាមអ៊ិនធ័រណិតរបស់សិស្ស ត្រូវតាមកម្រិតនៃការយល់ដឹងរបស់ពួកគេ។

ការប្រឡងសម្រាប់ PVA មានគ្រប់មុខវិទ្យាសំខាន់ៗផ្នែក ភាសា គណិតវិទ្យា វិទ្យាសាស្ត្រ និងប្រវត្តិវិទ្យា។ ហើយក៏មានការប្រឡងដើម្បីស្ទង់មើលពីចំណេះដឹងផ្នែក វេយ្យាករណ៍ភាសាអង់គ្លេស និងគណិតវិទ្យា ផងដែរ។ មានតែការប្រឡងដើម្បីស្ទង់មើលពីចំណេះដឹងផ្នែកភាសាអង់គ្លេស និងគណិតវិទ្យា ទេ ដែលគេតម្រូវឲ្យប្រឡងមុនពេលចុះឈ្មោះរៀននៅក្នុងវិជ្ជាស្ថាន។ បើសិនជាសិស្សចង់រៀនមុខវិទ្យាផ្សេងៗទៀត គេអាចសុំឲ្យពួកគេប្រឡងមុខវិទ្យាទាំងនោះនៅពេលចុះឈ្មោះ។

ការប្រឡងនីមួយៗចំណាយពេលប្រហែលជា ៣០នាទី។ ក្រោយពេលប្រឡងរួច ក្រុមអ្នកចុះឈ្មោះរបស់យើងខ្ញុំ នឹងសំណូមពរសុំឲ្យកូនលោកអ្នករៀនមុខវិជ្ជានីមួយៗ ក្នុងកម្រិតណាមួយ នៃកម្រិតបួន៖

| ១ | ២ | ៣ | ៤ |
|---|---|---|---|
| កម្រិត មូលដ្ឋាន (Anchors/Foundation) មុខវិជ្ជាដែលជាមូលដ្ឋាន នៃមុខវិជ្ជាដើម ដើម្បីឲ្យមានការងាយស្រួលក្នុងការអាន និងការយល់ដឹង | កម្រិត ត្រៀមសម្រាប់មហាវិទ្យាល័យ (College Prep) មុខវិជ្ជាដែលបង្រៀនតាមទម្លាប់ មុខវិជ្ជាដើម ដែលបានរៀបចំតាមកម្រិតថ្នាក់ | កម្រិត ពិសេស (Honors) មុខវិជ្ជាដែលផ្តល់សកម្មភាពរៀនបន្ថែម និងកិត្តិយសនៅលើ ព្រឹត្តិបត្រពិន្ទុរបស់សិស្ស | កម្រិត ខ្ពស់ (Advanced Placement (AP)) មុខវិជ្ជាដែលផ្តល់ឱកាសឲ្យសិស្សទទួលពិន្ទុសម្រាប់មហាវិទ្យាល័យ នៅពេលរៀនចប់មុខវិជ្ជាតាមរយៈការប្រឡង AP បានលទ្ធផលល្អសម្រាប់មុខវិជ្ជានោះ។ |

សខ្ចស

**តើកូនខ្ញុំត្រូវបានពិន្ទុនៃការប្រឡង យ៉ាងទាបបំផុតតាមការតម្រូវ ទើបអាចចុះឈ្មោះរៀននៅ PVA បានឬអ្វី?**
ភាគច្រើន គ្មានពិន្ទុកម្រិតទាបបំផុតប៉ុណ្ណោះទេ។ ទោះជាដូច្នេះក៏ដោយ មុខវិទ្យាសម្រាប់វិទ្យាល័យរបស់យើង បានរៀបចំឡើងសម្រាប់សិស្សានុសិស្សដែលអានបានប្រហែលកម្រិតសិស្សថ្នាក់ទី៧ ឬខ្ពស់ជាងនេះ។ មុខវិទ្យាសម្រាប់អនុវិទ្យាល័យរបស់យើង បានរៀបចំឡើងសម្រាប់សិស្សានុសិស្សដែលអានបានប្រហែលកម្រិតសិស្សថ្នាក់ទី៥ ឬខ្ពស់ជាងនេះ។ បើសិនជាការប្រឡងរបស់កូនលោកអ្នក មានកម្រិតក្រោមថ្នាក់មែនទែន ក្នុងការអាន ឬចំណេះដឹងផ្នែក គណិតវិទ្យា យើងយល់ថាមុខវិទ្យាដែលសិក្សាតាមអ៊ិនធ័រណិតនៅ PVA មិនមែនជាការចាត់តាំងដែលសក្តិសមសម្រាប់ពួកគេទេ ព្រោះអីការសិក្សាតាមអ៊ិនធ័រណិតត្រូវការអានយ៉ាងច្រើន។ ទោះជាយ៉ាងនេះក្តី គេនឹងពិភាក្សារឿងនេះជាមួយលោកអ្នក ហើយធ្វើការសម្រេចទៅតាមករណីនីមួយៗ។ សិស្សានុសិស្សដែលរៀនបានក្រោមកម្រិតថ្នាក់ ប៉ុន្តែមានសមត្ថភាពអាចសិក្សាតាមអ៊ិនធ័រណិត អាចទទួលជំនួយបន្ថែមតាមរយៈវិជ្ជាស្ថាន ដែលអាចជួយពួកគេឲ្យទទួលបានជោគជ័យ។

**តើអ្នកណាជាអ្នកបំពេញដំណាក់កាលនេះ?**

☐ លោកអ្នក (មាតាបិតា ឬអាណាព្យាបាល) ជាអ្នកបំពេញដំណាក់កាលនេះ។

សខ្ចស

**តើកូនខ្ញុំត្រូវរៀនមុខវិទ្យាទាំងអស់របស់ពួកគេតាមកម្រិតដូចគ្នា ឬ?**
មិនមែនទេ។ កូនរបស់លោកអ្នកអាចប្រឡងចូលកម្រិត មូលដ្ឋាន (Anchors) នៃមុខវិជ្ជាមួយ ហើយកម្រិត ពិសេស (Honors) នៃមុខវិជ្ជាផ្សេងទៀត។ លក្ខណៈបែបនេះអាចធ្វើទៅបាន នៅ PVA ហើយយើងខ្ញុំនឹងចុះឈ្មោះពួកគេសម្រាប់មុខវិជ្ជានីមួយៗឲ្យត្រូវតាមសេចក្តីត្រូវការរបស់ពួកគេ ទោះជាកម្រិត ជំនួយបន្ថែម (remedial) ឬកម្រិតខ្ពស់ (advanced) ក៏ដោយ។

តើលោកអ្នកមានសំណួរអ្វីផ្សេងទៀតអំពីវិធីនៃការចុះឈ្មោះនេះដែរឬទេ?
សូមទូរស័ព្ទទៅលេខ ២១៥-៤០០-៨៤៨៤ ដើម្បីទុកសារសម្លេង ឬផ្ញើសំណួរមកយើងខ្ញុំតាមវ៉ិបសៃ www.philasd.org/laguage/khmer/help យើងខ្ញុំនឹងទាក់ទងទៅលោកអ្នកវិញតាមការប្រញាប់ដែលអាចធ្វើទៅបាន។